លំហាត់ទី៥៩

គេមានអនុគមន៍ $f(x)=e^{x}.\sin x$

ក. ចូរគណនាដេរីវេ $f'(x)\ ,f''(x)\ ,f'''(x)$ និង $f^{(4)}(x)$ ។

ខ. ចូរបង្ហាញថាដេរីវេទី n នៃអនុគមន៍ f មានទម្រង់ $f^{(n)}(x)=(a_n\sin x+b_n\cos x).e^{x}$

ដែល (a_n) និង (b_n) ជាស្វ៊ីតចំនួនពិតផ្ទៀងផ្ទាត់ទំនាក់ទំនង $\begin{cases} a_{n+1}=a_n-b_n \\ b_{n+1}=a_n+b_n \end{cases}\ ,\forall n\in IN^*$

គ. គេតាង $z_n=a_n+i.b_n$ ។

ចូរបង្ហាញថា $z_{n+1}=(1+i).z_n$ រួចសរសេរ z_n ជាទម្រង់ត្រីកោណមាត្រ ។

ឃ. ចូរកំនត់ a_n និង b_n ជាអនុគមន៍នៃ n រួចទាញរកកន្សោម $f^{(n)}(x)$ ។

ដំណោះស្រាយ

ក. គណនាដេរីវេ $f'(x)\ ,f''(x)\ ,f'''(x)$ និង $f^{(4)}(x)$

គេមាន $f(x)=e^{x}.\sin x$

គេបាន $f'(x)=(e^{x})'\sin x+(\sin x)'e^{x}$

$$=e^{x}\sin x+\cos x.e^{x}=e^{x}(\sin x+\cos x)$$

ដូចនេះ $\boxed{f'(x)=e^{x}(\sin x+\cos x)}$ ។

គេបាន $f''(x)=(e^{x})'(\sin x+\cos x)+(\sin x+\cos x)'e^{x}$

$$=e^{x}(\sin x+\cos x)+(\cos x-\sin x)e^{x}$$

$$=e^{x}(\sin x+\cos x+\cos x-\sin x)=2e^{x}\cos x$$

ដូចនេះ $\boxed{f''(x)=2e^{x}\cos x}$ ។

គេបាន $f'''(x)=2(e^{x})'\cos x+2(\cos x)'e^{x}$

$$=2e^{x}\cos x-2\sin x.e^{x}=2e^{x}(\cos x-\sin x)$$

ដូចនេះ $\boxed{f'''(x) = 2e^x(\cos x - \sin x)}$ ។

គេបាន $f^{(4)}(x) = 2(e^x)'(\cos x - \sin x) + 2(\cos x - \sin x)'e^x$

$$= 2e^x(\cos x - \sin x) + 2(-\sin x - \cos x)e^x$$

$$= 2e^x(\cos x - \sin x - \sin x - \cos x) = -4e^x \sin x$$

ដូចនេះ $\boxed{f^{(4)}(x) = -4e^x \sin x}$ ។

ខ. បង្ហាញថាដេរីវេទី n នៃអនុគមន៍ f មានទម្រង់ $f^{(n)}(x) = (a_n \sin x + b_n \cos x).e^x$

តាមសម្រាយខាងលើគេមាន :

$f'(x) = e^x(\sin x + \cos x) = (\sin x + \cos x)e^x = (a_1 \sin x + b_1 \cos x)e^x$

ដែល $\begin{cases} a_1 = 1 \\ b_1 = 1 \end{cases}$

$f''(x) = 2e^x \cos x = (0.\sin x + 2\cos x)e^x = (a_2 \sin x + b_2 \cos x)e^x$

ដែល $\begin{cases} a_2 = 0 \\ b_2 = 2 \end{cases}$

$f'''(x) = 2e^x(\cos x - \sin x) = (-2\sin x + 2\cos x)e^x = (a_3 \sin x + b_3 \cos x)e^x$

ដែល $\begin{cases} a_3 = -2 \\ b_3 = 2 \end{cases}$

$f^{(4)}(x) = -4e^x \sin x = (-4\sin x + 0.\cos x)e^x = (a_4 \sin x + b_4 \cos x)e^x$

ដែល $\begin{cases} a_4 = -4 \\ b_4 = 0 \end{cases}$

....

ឧបមាថាវាពិតដល់ដេរីវេលំដាប់ទី n គឺ $f^{(n)}(x) = (a_n \sin x + b_n \cos x).e^x$ ពិត

យើងនឹងស្រាយថាវាពិតដល់ដេរីវេលំដាប់ទី $(n+1)$ គឺ

$f^{(n+1)}(x) = (a_{n+1} \sin x + b_{n+1} \cos x)e^x$

យើងមាន $f^{(n+1)}(x)=(f^{(n)}(x))'$

$$=(a_n\sin x+b_n\cos x)'e^x+(e^x)'(a_n\sin x+b_n\cos x)$$

$$f^{(n+1)}(x)=(a_n\cos x-b_n\sin x)e^x+e^x(a_n\sin x+b_n\cos x)$$
$$=(a_n\cos x-b_n\sin x+a_n\sin x+b_n\cos x)e^x$$
$$=\left[(a_n-b_n)\sin x+(a_n+b_n)\cos x\right].e^x$$

$f^{(n+1)}(x)=(a_{n+1}\sin x+b_{n+1}\cos x).e^x$ ពិត

(ព្រោះ $a_{n+1}=a_n-b_n$ និង $b_{n+1}=a_n+b_n$)

ដូចនេះ ដេរីវេទី n នៃអនុគមន៍ f មានទម្រង់ $f^{(n)}(x)=(a_n\sin x+b_n\cos x).e^x$

ដែល (a_n) និង (b_n) ជាស្វ៊ីតចំនួនពិតផ្ទៀងផ្ទាត់ទំនាក់ទំនង $\begin{cases}a_{n+1}=a_n-b_n\\ b_{n+1}=a_n+b_n\quad,\forall n\in IN^*\end{cases}$

គ. បង្ហាញថា $z_{n+1}=(1+i).z_n$

គេមាន $z_n=a_n+i.b_n$ នាំឱ្យ $z_{n+1}=a_{n+1}+i.b_{n+1}$

ដោយ $\begin{cases}a_{n+1}=a_n-b_n\\ b_{n+1}=a_n+b_n\quad,\forall n\in IN^*\end{cases}$

គេបាន $z_{n+1}=(a_n-b_n)+i.(a_n+b_n)$
$$=a_n-b_n+i.a_n+i.b_n$$
$$=(1+i)a_n-(1-i)b_n$$
$$=(1+i)(a_n-\frac{1-i}{1+i}b_n)$$
$$=(1+i)(a_n+i.b_n)=(1+i)z_n$$

ដូចនេះ $\boxed{z_{n+1}=(1+i)z_n}$ ។

សរសេរ z_n ជាទម្រង់ត្រីកោណមាត្រ :

ដោយគេមាន $z_{n+1}=(1+i).z_n$ នាំឱ្យ (z_n) ជាស្វ៊ីតធរណីមាត្រនៃចំនួនកុំផ្លិចដែលមានរេសុង

$q=1+i=\sqrt{2}(\frac{\sqrt{2}}{2}+i.\frac{\sqrt{2}}{2})=\sqrt{2}(\cos\frac{\pi}{4}+i.\sin\frac{\pi}{4})$ និងតួ $z_1=a_1+ib_1$

តែ $a_1=1, b_1=1$ នាំឱ្យ $z_1=1+i=q=\sqrt{2}(\cos\frac{\pi}{4}+i.\sin\frac{\pi}{4})$ ។

តាមរូបមន្តតួទី n នៃស្វ៊ីតធរណីមាត្រគេអាចសរសេរ :

$$z_n=z_1\times q^{n-1}=\sqrt{2}(\cos\frac{\pi}{4}+i.\sin\frac{\pi}{4}).\left[\sqrt{2}(\cos\frac{\pi}{4}+i.\sin\frac{\pi}{4})\right]^{n-1}$$

$$=(\sqrt{2})^n(\cos\frac{\pi}{4}+i.\sin\frac{\pi}{4})^n$$

ដូចនេះ $\boxed{z_n=\sqrt{2^n}(\cos\frac{n\pi}{4}+i.\sin\frac{n\pi}{4})}$ (តាមរូបមន្តដឺម័រ) ។

ឃ. កំនត់ a_n និង b_n ជាអនុគមន៍នៃ n

គេមាន $z_n=a_n+i.b_n$ ដោយ $z_n=\sqrt{2^n}(\cos\frac{n\pi}{4}+i.\sin\frac{n\pi}{4})$

គេទាញ $a_n+i.b_n=\sqrt{2^n}(\cos\frac{n\pi}{4}+i.\sin\frac{n\pi}{4})$ នាំឱ្យ $\begin{cases} a_n=\sqrt{2^n}.\cos\frac{n\pi}{4} \\ b_n=\sqrt{2^n}.\sin\frac{n\pi}{4} \end{cases}$

ដូចនេះ $\boxed{a_n=\sqrt{2^n}.\cos\frac{n\pi}{4}\ ,b_n=\sqrt{2^n}.\sin\frac{n\pi}{4}}$ ។

ទាញរកកន្សោម $f^{(n)}(x)$:

គេមាន $f^{(n)}(x)=(a_n\sin x+b_n\cos x)e^x$

ដោយ $a_n=\sqrt{2^n}.\cos\frac{n\pi}{4}\ ,b_n=\sqrt{2^n}.\sin\frac{n\pi}{4}$

គេបាន $f^{(n)}(x)=(\sqrt{2^n}.\cos\frac{n\pi}{4}.\sin x+\sqrt{2^n}\cos x.\sin\frac{n\pi}{4}).e^x$

$$=\sqrt{2^n}(\cos\frac{n\pi}{4}\sin x+\sin\frac{n\pi}{4}\cos x).e^x=\sqrt{2^n}.\sin(x+\frac{n\pi}{2}).e^x$$

ដូចនេះ $\boxed{f^{(n)}(x)=\sqrt{2^n}.e^x\sin(x+\frac{n\pi}{4})}$ ។

លំហាត់ទី៦០

គេឱ្យអនុគមន៍ $f(x)=\ln\left(\frac{1-x}{1+x}\right)$, $-1<x<1$

ក. ចំពោះគ្រប់ $a,b\in]-1,1[$ ចូរបង្ហាញថា $f(a)+f(b)=f(\frac{a+b}{1+ab})$

ខ. ចូរគណនា $S_n=f(\frac{1}{2})+f(\frac{1}{3})+f(\frac{1}{4})+......+f(\frac{1}{n})$ ជាអនុគមន៍នៃ n ។

ដំណោះស្រាយ

ក-បង្ហាញថា $f(a)+f(b)=f(\frac{a+b}{1+ab})$

យើងបាន $f(a)+f(b)=\ln(\frac{1-a}{1+a})+\ln(\frac{1-b}{1+b})$

$$=\ln\left[\frac{(1-a)(1-b)}{(1+a)(1+b)}\right]=\ln\left(\frac{1-(a+b)+ab}{1+(a+b)+ab}\right)$$

$$=\ln[\frac{(1+ab)-(a+b)}{(1+ab)+(a+b)}]==\ln(\frac{1-\frac{a+b}{1+ab}}{1+\frac{a+b}{1+ab}})=f(\frac{a+b}{1+ab})$$

ដូចនេះ $\boxed{f(a)+f(b)=f(\frac{a+b}{1+ab})}$ ។

ខ. គណនា S_n ជាអនុគមន៍នៃ n

$$S_n=f(\frac{1}{2})+f(\frac{1}{3})+f(\frac{1}{4})+......+f(\frac{1}{n})=\sum_{k=1}^{n}\left[f(\frac{1}{k})\right]$$

$$=\sum_{k=2}^{n}[\ln(\frac{1-\frac{1}{k}}{1+\frac{1}{k}})]=\sum_{k=2}^{n}[\ln(\frac{k-1}{k+1})]$$

$$=\ln(\frac{1}{3})+\ln(\frac{2}{4})+\ln(\frac{3}{5})+\ln(\frac{4}{6})+...+\ln(\frac{n-3}{n-1})+\ln(\frac{n-2}{n})+\ln(\frac{n-1}{n+1})$$

$$=\ln\left(\frac{1}{3}.\frac{2}{4}.\frac{3}{5}.\frac{4}{3}....\frac{n-3}{n-1}.\frac{n-2}{n}.\frac{n-1}{n+1}\right)=\ln\left(\frac{2}{n(n+1)}\right)$$

ដូចនេះ $\boxed{S_n=f(\frac{1}{2})+f(\frac{1}{3})+f(\frac{1}{4})+......+f(\frac{1}{n})=\ln\left(\frac{2}{n(n+1)}\right)}$ ។

លំហាត់ទី៦១

គេឱ្យអនុគមន៍ $f(x)=\frac{x}{\sqrt[3]{1+x^3}}$, $x\neq -1$

ចូរគណនា $F_n(x)=f\big[\ f\ [.....f\ [f(x)].....]\ \big]$ ។

ដំណោះស្រាយ

គណនា $F_n(x)=f\big[\ f\ [.....f\ [f(x)].....]\ \big]$

យើងមាន $F_1(x)=f(x)=\frac{x}{\sqrt[3]{1+x^3}}$

$$F_2(x)=f\left[f(x)\right]=f\left[F_1(x)\right]$$

$$F_3(x)=f\left[f\left[f(x)\right]\right]=f\left[F_2(x)\right]$$

$$----------------$$

$$F_n(x)=f\left[F_{n-1}(x)\right]=\frac{F_{n-1}(x)}{\sqrt[3]{1+F_{n-1}^3(x)}}$$

យើងបាន $F_n^3(x)=\frac{F_{n-1}^3(x)}{1+F_{n-1}^3(x)}$ នាំឱ្យ $\frac{1}{F_n^3(x)}=\frac{1+F_{n-1}^3(x)}{F_{n-1}^3(x)}=\frac{1}{F_{n-1}^3(x)}+1$

គេទាញ $\frac{1}{F_n^3(x)}-\frac{1}{F_{n-1}^3(x)}=1$ ថេរ នាំឱ្យគេទាញបានថា $\left(\frac{1}{F_n^3(x)}\right)$

ជាស្វ៊ីតនព្វន្តមានផលសងរួម $d=1$ និងតួទីមួយ $U_1=\frac{1}{F_1{}^3(x)}=\frac{1+x^3}{x^3}$ ។

តាមរូបមន្ត $U_n=U_1+(n-1).d$ គេបាន $\frac{1}{F_n{}^3(x)}=\frac{1+x^3}{x^3}+n-1=\frac{1+nx^3}{x^3}$

គេទាញ $F_n{}^3(x)=\sqrt[3]{\frac{x^3}{1+nx^3}}=\frac{x}{\sqrt[3]{1+nx^3}}$

ដូចនេះ $\boxed{F_n(x)=f\big[\ f\ [.....f\ [f(x)].....]\ \big]=\frac{x}{\sqrt[3]{1+nx^3}}}$ ។

លំហាត់ទី៦២

គេមានពហុធា $P_n(x)=(x\sin\theta+\cos\theta)^n$, $\theta\in IR$, $n\geq 2$

ចូររកសំណល់នៃវិធីចែករវាងពហុធា $P_n(x)$ និង x^2+1 ។

ដំណោះស្រាយ

រកសំណល់នៃវិធីចែករវាងពហុធា $P_n(x)$ និង x^2+1

តាង $R(x)$ ជាអនុគមន៍សំណល់នៃវិធីចែករវាងពហុធា $P_n(x)$ និង x^2+1

នាំឱ្យអនុគមន៍ $R(x)$ ត្រូវមានដឺក្រេតូចជាងឬស្មើមួយ ។

យក $R(x)=ax+b$ ដែល a និង b ជាចំនួនពិតត្រូវរកហើយឧបមាថា $Q(x)$ ជាអនុគមន៍

ផលចែក រវាងពហុធា $P_n(x)$ និង x^2+1 នោះគេបានទំនាក់ទំនង :

$$P_n(x)=Q(x).(x^2+1)+R(x)$$

$$(x\sin\theta+\cos\theta)^n=Q(x).(x^2+1)+ax+b$$

យើងជ្រើសរើសយក $x=i$ ដែល $i^2=-1$ យើងបាន :

$$(i.\sin\theta+\cos\theta)^n=Q(i)(i^2+1)+ai+b$$

$$i.\sin(n\theta)+\cos(n\theta)=ai+b$$

ព្រោះ $(i.\sin\theta+\cos\theta)^n=i.\sin(n\theta)+\cos(n\theta)$ (រូបមន្តដឺម័រ)

គេទាញបាន $a=\sin(n\theta)$, $b=\cos(n\theta)$ ។

ដូចនេះ $\boxed{R(x)=x.\sin(n\theta)+\cos(n\theta)}$ ។

លំហាត់ទី៦៣

គេឲ្យស៊ីតនៃចំនួនពិត $(U_n)_{n\in IN}$ ដោយ $U_{n+1}=\frac{7U_n^3-9U_n^2+3U_n}{6U_n^3-6U_n^2+1}$ និង $U_1=2$

ក_គេតាង $V_n=\frac{U_n-1}{2U_n-1}\ ,\forall n\in IN^*$ ។ ចូរបង្ហាញថា $V_{n+1}=V_n^3$

ខ_គេយក $W_n=\ln V_n\ ,\forall n\in IN^*$ ។ ចូរបង្ហាញថា $(W_n)_{,n\in IN}$ ជាស៊ីតធរណីមាត្រ រួចគណនា W_n ជាអនុគមន៍នៃ n ។

គ_ចូរទាញរក V_n និង U_n ជាអនុគមន៍នៃ n រួចគណនា $\lim_{n\to+\infty}U_n$ ។

ដំណោះស្រាយ

ក_ បង្ហាញថា ៖ $V_{n+1}=V_n^3$

យើងមាន $V_n=\frac{U_n-1}{2U_n-1}\ ,\forall n\in IN^*$

យើងបាន $V_{n+1}=\frac{U_{n+1}-1}{2U_{n+1}-1}$ ដោយ $U_{n+1}=\frac{7U_n^3-9U_n^2+3U_n}{6U_n^3-6U_n^2+1}$

$$V_{n+1}=\frac{\frac{7U_n^3-9U_n^2+3U_n}{6U_n^3-6U_n^2+1}-1}{2\left(\frac{7U_n^3-9U_n^2+3U_n}{6U_n^3-6U_n^2+1}\right)-1}$$

$$V_{n+1}=\frac{7U_n^3-9U_n^2+3U_n-6U_n^3+6U_n^2-1}{14U_n^3-18U_n^2+6U_n-6U_n^3+6U_n^2-1}$$

$$V_{n+1}=\frac{U_n^3-3U_n^2+3U_n-1}{8U_n^3-12U_n^2+6U_n-1}=\frac{(U_n-1)^3}{(2U_n-1)^3}=\left(\frac{U_n-1}{2U_n-1}\right)^3$$

ដូចនេះ $V_{n+1}=V_n^3$ ។

ខ_បង្ហាញថា $(W_n)_{,n\in IN}$ ជាស៊ីតធរណីមាត្រ ៖

យើងមាន $W_n=\ln V_n$ នាំឲ្យ $W_{n+1}=\ln V_{n+1}$ ដោយ $V_{n+1}=V_n^3$

យើងបាន $W_{n+1}=\ln V_n^3=3\ln V_n=3W_n$

ដូចនេះ $(W_n)_{,n\in IN}$ ជាស៊ីតធរណីមាត្រដែលមានរេសុង $q=3$ ។

_គណនា W_n ជាអនុគមន៍នៃ n ៖

តាមរូបមន្ត $W_n = W_1 \times q^{n-1}$

ដោយ $W_1 = \ln V_1 = \ln\left(\frac{U_1 - 1}{2U_1 - 1}\right) = \ln(\frac{2-1}{4-1}) = \ln(\frac{1}{3})$ និង $q = 3$

យើងបាន $W_n = \ln(\frac{1}{3}) \times (3)^n = 3^n \ln(\frac{1}{3})$ ។

គ_ទាញរក V_n និង U_n ជាអនុគមន៍នៃ n ៖

យើងមាន $W_n = \ln V_n$ ដោយ $W_n = 3^n \ln(\frac{1}{3})$

យើងបាន $\ln V_n = 3^n \ln(\frac{1}{3})$ នាំឲ្យ $V_n = \left(\frac{1}{3}\right)^{3^n}$

ម្យ៉ាងទៀត $V_n = \frac{U_n - 1}{2U_n - 1}$ នាំឲ្យ $U_n = \frac{1 - V_n}{1 - 2V_n} = \frac{1 - (\frac{1}{3})^{3^n}}{1 - 2(\frac{1}{3})^{3^n}} = \frac{3^{3^n} - 1}{3^{3^n} - 2}$

ដូចនេះ $V_n = \left(\frac{1}{3}\right)^{3^n}$ និង $U_n = \frac{3^{3^n} - 1}{3^{3^n} - 2}$ ។

_គណនាលីមីត ៖ $\lim\limits_{n \to +\infty} U_n$

យើងមាន $U_n = \frac{3^{3^n} - 1}{3^{3^n} - 2}$

យើងបាន $\lim\limits_{n \to +\infty} U_n = \lim\limits_{n \to +\infty}\left(\frac{3^{3^n} - 1}{3^{3^n} - 2}\right) = \lim\limits_{n \to +\infty} \frac{1 - \frac{1}{3^{3^n}}}{1 - \frac{2}{3^{3^n}}} = 1$

ដូចនេះ $\lim\limits_{n \to +\infty} U_n = 1$ ។

✍📖📖📖📖✍

លំហាត់ទី៦៤

គេឲ្យអនុគមន៍ f កំនត់ក្នុងសំណុំ IR ដោយ $f(x)=\dfrac{x^3}{3(x^2+3x+3)}$

ក_គេពិនិត្យស្វ៊ីត (U_n) កំនត់ដោយ $U_{n+1}=f(U_n)$ ចំពោះគ្រប់ $n\in IN^*$ ។

ចូរស្រាយបញ្ជាក់ទំនាក់ទំនង $1+\dfrac{3}{U_{n+1}}=\left(1+\dfrac{3}{U_n}\right)^3$ ។

ខ_គេតាង $F_n(x)=f_n[f\ [......f[f(x)]......]]$ (អនុគមន៍បណ្ដាក់លំដាប់ n)

ចូរគណនា $F_n(x)$ ។

គ_គេសន្មតថា $U_1=\dfrac{3}{7}$ និង $V_n=\ln(3+U_n)-\ln U_n$ ចំពោះគ្រប់ $n\in IN^*$ ។

ចូរបង្ហាញថា (V_n) ជាស្វ៊ីតធរណីមាត្រ រួចគណនា V_n ជាអនុគមន៍នៃ n ។

ឃ_ទាញរក U_n ជាអនុគមន៍នៃ n រួចបញ្ជាក់តម្លៃ $\lim\limits_{n\to+\infty}U_n$ ។

ដំណោះស្រាយ

ក_ស្រាយបញ្ជាក់ទំនាក់ទំនង $1+\dfrac{3}{U_{n+1}}=\left(1+\dfrac{3}{U_n}\right)^3$

យើងមាន $U_{n+1}=f(U_n)$ ដោយ $f(x)=\dfrac{x^3}{3(x^2+3x+3)}$

យើងបាន $U_{n+1}=\dfrac{U_n{}^3}{3(U_n{}^2+3U_n+3)}$ (1)

ម្យ៉ាងទៀត $U_{n+1}+3=\dfrac{U_n{}^3}{3(U_n{}^2+3U_n+3)}+3$

$$U_{n+1}+3=\frac{U_n{}^3+9U_n{}^2+27U_n+27}{3(U_n{}^2+3U_n+3)}$$

$$U_{n+1}+3=\frac{(U_n+3)^3}{3(U_n{}^2+3U_n+3)} \quad (2)$$

ចែកទំនាក់ទំនង (2) និង (1) អង្គនិងអង្គយើងបាន ៖

$\dfrac{U_{n+1}+3}{U_{n+1}}=\dfrac{(U_n+3)^3}{U_n{}^3}$ ឬ $1+\dfrac{3}{U_{n+1}}=\left(1+\dfrac{3}{U_n}\right)^3$ ។

ខ_គណនា $F_n(x)$ ៖

យើងមាន $F_n(x) = f_n[f\ [......f[f(x)]......]]$ (អនុគមន៍បណ្ដាក់លំដាប់ n)

ចំពោះគ្រប់ $n \in IN^*$ យើងយក ៖

$$U_1 = f(x) = \frac{x^3}{3(x^2+3x+3)}$$
$$U_2 = f[f(x)] = f(U_1)$$
$$U_3 = f[f[f(x)]] = f(U_2)$$
$$-----------------$$
$$U_n = f[f[........f[f(x)]......]] = f(U_{n-1})$$
$$U_{n+1} = f(U_n) = \frac{U_n{}^3}{3(U_n{}^2+3U_n+3)}$$

ដូចនេះគេទាញ $F_n(x) = f[f[........f[f(x)]........]] = U_n$

តាមសម្រាយខាងលើគេមាន $1+\dfrac{3}{U_{n+1}} = \left(1+\dfrac{3}{U_n}\right)^3$

គេបាន $\ln\left(1+\dfrac{3}{U_{n+1}}\right) = 3\ln\left(1+\dfrac{3}{U_n}\right)$ ដោយតាង $T_n = \ln\left(1+\dfrac{3}{U_n}\right)$

គេបាន $T_{n+1} = 3T_n$ នាំឲ្យ (T_n) ជាស្វ៊ីតធរណីមាត្រមានរេសុង $q = 3$

និងតួ $T_1 = \ln\left(1+\dfrac{3}{U_1}\right) = \ln\left(1+\dfrac{3}{f(x)}\right) = \ln\left(1+\dfrac{9x^2+27x+27}{x^3}\right) = \ln\left(\dfrac{x+3}{x}\right)^3$

តាមរូបមន្ត $T_n = T_1 \times q^{n-1} = 3^{n-1}.\ln\left(\dfrac{x+3}{x}\right)^3 = \ln\left(\dfrac{x+3}{x}\right)^{3^n}$

តែ $T_n = \ln\left(1+\dfrac{3}{U_n}\right)$ គេទាញ $1+\dfrac{3}{U_n} = \left(\dfrac{x+3}{x}\right)^{3^n}$

នាំឲ្យ $U_n = \dfrac{3}{\left(\dfrac{x+3}{x}\right)^{3^n} - 1} = \dfrac{3x^{3^n}}{(x+3)^{3^n} - x^{3^n}}$

ដូចនេះ $\boxed{F_n(x) = f[f[........f[f(x)]........]] = \dfrac{3x^{3^n}}{(x+3)^{3^n} - x^{3^n}}}$ ។

គ_បង្ហាញថា (V_n) ជាស្វ៊ីតធរណីមាត្រ ៖

គេមាន $U_1 = 3$ និង $V_n = \ln(3+U_n) - \ln U_n$ ចំពោះគ្រប់ $n \in IN^*$

យើងបាន $V_n = \ln\left(\frac{3+U_n}{U_n}\right) = \ln\left(1+\frac{3}{U_n}\right)$

នាំឲ្យ $V_{n+1} = \ln\left(1+\frac{3}{U_{n+1}}\right)$ ដោយ $1+\frac{3}{U_{n+1}} = \left(1+\frac{3}{U_n}\right)^3$

គេបាន $V_{n+1} = \ln\left(1+\frac{3}{U_n}\right)^3 = 3\ln\left(1+\frac{3}{U_n}\right) = 3V_n$

ដូចនេះ (V_n) ជាស្វ៊ីតធរណីមាត្រមានរេសុង $q = 3$

និងតួ $V_1 = \ln\left(1+\frac{3}{U_1}\right) = \ln 8$ ។

_គណនា V_n ជាអនុគមន៏នៃ n ៖

តាមរូបមន្ត $V_n = V_1 \times q^{n-1} = 3^{n-1}.\ln 8 = 3^n \ln 2$ ។

ឃ_ទាញរក U_n ជាអនុគមន៏នៃ n រួចបញ្ជាក់តម្លៃ $\lim\limits_{n\to+\infty} U_n$ ៖

គេមាន $V_n = \ln\left(1+\frac{3}{U_n}\right)$ ដោយ $V_n = 3^n \ln 2 = \ln(2)^{3^n}$

គេទាញ $1+\frac{3}{U_n} = (2)^{3^n}$ នាំឲ្យ $U_n = \frac{3}{2^{3^n}-1}$ ។

ដូចនេះ $\boxed{U_n = \frac{3}{2^{3^n}-1}}$ និង $\lim\limits_{n\to+\infty} U_n = 0$ ។

✍✍✍✍✍✍

លំហាត់ទី៦៥

គេឲ្យស៊ីតនៃចំនួនពិត $U_n=\sqrt{6+\sqrt{6+\sqrt{6+....+\sqrt{6+\sqrt{6}}}}}$ មាន n រ៉ាឌីកាល់ ។

ចូរស្រាយថា $U_n<3$ ចំពោះគ្រប់ $n\in IN$ ។

ដំណោះស្រាយ

ស្រាយថា $U_n<3$ ចំពោះគ្រប់ $n\in IN$

សម្មតិកម្ម $U_n=\sqrt{6+\sqrt{6+\sqrt{6+....+\sqrt{6+\sqrt{6}}}}}$

យើងមាន $U_1=\sqrt{6}<3$ ពិត

$U_2=\sqrt{6+\sqrt{6}}=\sqrt{6+U_1}<\sqrt{6+3}<3$ ពិត ។

សន្មតថាវាពិតដល់តួទី k គឺ $U_k=\sqrt{6+\sqrt{6+...+\sqrt{6}}}<3$

យើងនឹងស្រាយថាវាពិតដល់តួទី $k+1$ គឺ $U_{k+1}=\sqrt{6+\sqrt{6+\sqrt{6+....+\sqrt{6}}}}<3$

យើងមាន $U_{k+1}=\sqrt{6+U_k}$ ដោយ $U_k<3$ នាំឲ្យ $6+U_k<9$

គេទាញបាន $U_{k+1}=\sqrt{6+U_k}<3$ ពិត ។

ដូចនេះ $U_n<3$ ចំពោះគ្រប់ $n\in IN$ ។

លំហាត់អនុវត្តន៍

១_គេឲ្យ $x_0=\sqrt{2}$; $x_1=\sqrt{3}$ និង $x_n=\frac{x_{n-1}+x_{n-2}}{2}$ ចំពោះគ្រប់ $n\geq 2$ ។

ចូរស្រាយថា $\lim\limits_{n\to+\infty} x_n=\frac{\sqrt{2}+2\sqrt{3}}{3}$ ។

២_គេឲ្យ $a_1=7$; $a_2=4$ និង $4a_{n+2}-5a_{n+1}+a_n=0$ ចំពោះគ្រប់ $n\geq 1$ ។

ដោយសរសេរទំនាក់ទំនងក្នុងទម្រង់ $a_{n+2}-a_{n+1}=\frac{1}{4}(a_{n+1}-a_n)$ ចូរស្រាយថា ៖

$a_{n+1}-a_n=-3\left(\frac{1}{4}\right)^{n-1}$ បន្ទាប់មកគណនា a_n និងបង្ហាញថា $\lim\limits_{n\to+\infty} a_n=3$ ។

៣_គេឲ្យ $f_n(x)=\frac{x(x+1)(x+2)......(x+n-1)}{n!}$

ក.ដោយធ្វើវិចារតាមកំនើនចូរស្រាយថា ៖

$(i):\sum\limits_{n=1}^{N} f_n(x)=f_N(x)-1$

$(ii)\;\; 0<f_N(x)<\frac{1}{\sqrt{2N+1}}$

ខ. ដោយយក $x=-\frac{1}{2}$ ចូរស្រាយថា ៖

$$\lim_{n\to+\infty}\left[\frac{1}{2.4}+\frac{1.3}{2.4.6}+\frac{1.3.5}{2.4.6.8}+.....+\frac{1.3.5.....(2n-1)}{2.4.6.....(2n+2)}\right]=\frac{1}{2}$$ ។

៤_គេឲ្យស្វីតចំនួនពិត (x_n) និង (y_n) កំនត់ដោយ ៖

$x_1=y_1=1$; $x_{n+1}=x_n+2y_n$ និង $y_{n+1}=x_n+y_n$ ចំពោះគ្រប់ $n\in IN^*$

ក.ចូរស្រាយថា $\forall n\in IN^*$: $x_n\geq n$; $y_n\geq n$ និង $x_n{}^2-y_n{}^2=(-1)^n$ ។

ខ.ទាញថា $\frac{x_n}{y_n}<\sqrt{2}$ បើ n គូ និង $\frac{x_n}{y_n}>\sqrt{2}$ បើ n សេស ។

បង្ហាញថា $\lim\limits_{n\to+\infty}\frac{x_n}{y_n}=\sqrt{2}$ ។

គ.ចូរបង្ហាញថា $\left|\frac{x_{n+1}}{y_{n+1}}-\sqrt{2}\right|<\left|\frac{x_n}{y_n}-\sqrt{2}\right|$ ។

៥_គេឲ្យស្វ៊ីតនៃចំនួនពិត (u_n) កំនត់ដោយ $\begin{cases} u_0 = 4 \\ u_{n+1} = \sqrt{u_n} \end{cases}, \forall n \in IN$

ក.បង្ហាញថាស្វ៊ីត $v_n = \ln u_n$ ជាស្វ៊ីតធរណីមាត្រ ។

ខ.គណនា v_n និង u_n ជាអនុគមន៍នៃ n ។

គ.គណនា $S_n = v_0 + v_1 + ... + v_n$ និង $P_n = u_0.u_1.u_2.....u_n$ ជាអនុគមន៍នៃ n ។

៦_គេឲ្យស្វ៊ីតនៃចំនួនពិត (u_n) កំនត់ដោយ $\begin{cases} u_0 = 8 \\ u_{n+1} = \sqrt[3]{u_n^{\ 2}} \end{cases}, \forall n \in IN$

ក.បង្ហាញថាស្វ៊ីត $v_n = \ln u_n$ ជាស្វ៊ីតធរណីមាត្រ ។

ខ.គណនា v_n និង u_n ជាអនុគមន៍នៃ n ។

គ.គណនា $S_n = v_0 + v_1 + ... + v_n$ និង $P_n = u_0.u_1.u_2.....u_n$ ជាអនុគមន៍នៃ n ។

៧_គេឲ្យស្វ៊ីតនៃចំនួនពិត (u_n) កំនត់ដោយ $\begin{cases} u_0 = 2 \\ u_{n+1} = \dfrac{2}{3}u_n - \dfrac{2}{3} \end{cases}, \forall n \in IN$

ក.បង្ហាញថាស្វ៊ីត $v_n = 2 + u_n$ ជាស្វ៊ីតធរណីមាត្រ ។

ខ.គណនា v_n និង u_n ជាអនុគមន៍នៃ n ។

៨_គេឲ្យស្វ៊ីតនៃចំនួនពិត (u_n) កំនត់ដោយ $\begin{cases} u_0 = 2 \\ u_{n+1} = -\dfrac{1}{4}u_n + 3 \end{cases}, \forall n \in IN$

ក.កំនត់តម្លៃ k ដើម្បីឲ្យ $v_n = u_n + k$ ជាស្វ៊ីតធរណីមាត្រ ។

ខ.គណនា u_n ជាអនុគមន៍នៃ n និងរក $\lim\limits_{n \to +\infty} u_n$ ។

៩_គេមានស្វ៊ីត $\begin{cases} u_0 = 2 \\ u_{n+1} = u_n^{\ 2} + 4u_n + 2 \end{cases}, \forall n \in IN$

ក.បង្ហាញថាស្វ៊ីត $v_n = \ln(2 + u_n)$ ជាស្វ៊ីតធរណីមាត្រ ។

ខ.គណនា v_n និង u_n ជាអនុគមន៍នៃ n ។

គ.គណនា $S_n = v_0 + v_1 + ... + v_n$

និង $P_n = (2+u_0)(2+u_1).....(2+u_n)$ ជាអនុគមន៍នៃ n ។

១០_គេឲ្យស្វ៊ីត $\begin{cases} u_0 = 3 \\ u_{n+1} = -\frac{1}{3}u_n + 2n + 7 \ , n \in IN \end{cases}$

ចូរគណនា u_n ជាអនុគមន៍នៃ n ។

១១_គេឲ្យស្វ៊ីត $\begin{cases} u_0 = 1 \\ u_{n+1} = \frac{1}{2}u_n + n^2 - 2n + 4 \ , n \in IN \end{cases}$

ចូរគណនា u_n ជាអនុគមន៍នៃ n ។

១២_គេឲ្យស្វ៊ីត $\begin{cases} u_0 = 1 \\ u_{n+1} = -\frac{1}{2}u_n + (3n-1).2^n \ , n \in IN \end{cases}$

ចូរគណនា u_n ជាអនុគមន៍នៃ n ។

១៣_គេឲ្យស្វ៊ីត $\begin{cases} u_0 = 0 \\ u_{n+1} = \frac{1}{2}u_n + \sin\frac{n\pi}{4} \ , n \in IN \end{cases}$

ចូរគណនា u_n ជាអនុគមន៍នៃ n ។

១៤_គេឲ្យស្វ៊ីត $\begin{cases} u_0 = 2 \\ u_{n+1} = 3u_n + \sqrt{2}\cos\frac{n\pi}{4} \ , n \in IN \end{cases}$

ចូរគណនា u_n ជាអនុគមន៍នៃ n ។

១៥_គេឲ្យស្វ៊ីត $\begin{cases} u_0 = 1 \\ u_{n+1} = {u_n}^2 + 6u_n + 6 \ , n \in IN \end{cases}$

ចូរគណនា u_n ជាអនុគមន៍នៃ n ។

១៦_គេមានស្វ៊ីត $\begin{cases} u_0 = 3 \\ u_{n+1} = \frac{5u_n - 2}{u_n + 2}, \forall n \in IN \end{cases}$

ក.បង្ហាញថាស្វ៊ីត $v_n = \frac{u_n - 1}{u_n - 2}$ ជាស្វ៊ីតធរណីមាត្រ ។

ខ.គណនា v_n និង u_n ជាអនុគមន៍នៃ n ។

១៧_គេឲ្យស៊ីត $\begin{cases} u_0 = 4 \\ u_{n+1} = \dfrac{2(2u_n - 3)}{u_n - 1} \end{cases}$, $n \in IN$

គណនា u_n ជាអនុគមន៍នៃ n និងរក $\lim\limits_{n\to+\infty} u_n$ ។

១៨_គេឲ្យស៊ីត $\begin{cases} u_0 = 4 \\ u_{n+1} = u_n^3 - 6u_n^2 + 12u_n - 6 \end{cases}$, $\forall n \in IN$

ក.ស្រាយថា $v_n = \ln(u_n - 2)$ ជាស៊ីតធរណីមាត្រ ។

ខ.គណនា v_n និង u_n ជាអនុគមន៍នៃ n ។

១៩_គេឲ្យស៊ីត $\begin{cases} u_1 = 2 \\ u_{n+1} + u_n = \dfrac{(-1)^n}{4n^2 - 1} \end{cases}$, $n \in IN$

គណនា u_n ជាអនុគមន៍នៃ n និងរក $\lim\limits_{n\to+\infty} u_n$ ។

២០_គេឲ្យស៊ីត $\begin{cases} u_1 = \dfrac{1}{2} \\ u_{n+1} = \dfrac{n+1}{2n} u_n \end{cases}$, $n \in IN^*$

ក.ស្រាយថា $v_n = \dfrac{u_n}{n}$ ជាស៊ីតធរណីមាត្រ ។

ខ.គណនា v_n និង u_n ជាអនុគមន៍នៃ n ។

២១_គេឲ្យស៊ីត $u_n = \dfrac{3n^2 + 3n + 1}{n^3(n+1)^3}$, $\forall n \in IN^*$

ក. បង្ហាញថា $u_n = \dfrac{1}{n^3} - \dfrac{1}{(n+1)^3}$

ខ. គណនា $S_n = u_1 + u_2 + ... + u_n$ ជាអនុគមន៍នៃ n រួចទាញរក $\lim\limits_{n\to+\infty} S_n$ ។

២២_គេឲ្យស៊ីត $\begin{cases} u_1 = 4 \\ u_{n+1} - u_n = \dfrac{3n^2 + 3n + 1}{n^3(n+1)^3} \end{cases}$, $n \in IN^*$

គណនា u_n ជាអនុគមន៍នៃ n និងរក $\lim\limits_{n\to+\infty} u_n$ ។

២៣_គេឲ្យស៊ីត $\begin{cases} u_1 = 2 \\ u_{n+1} = \dfrac{(n+1)^3 - 1}{(n+1)^3 + 1} u_n \end{cases}$, $n \in IN^*$

គណនា u_n ជាអនុគមន៍នៃ n និងរក $\lim\limits_{n\to+\infty} u_n$ ។

២៤_គេឲ្យស៊ីតនៃចំនួនពិត $\begin{cases} u_0 = 2 \ , \ u_1 = 6 \\ u_{n+2} = 6u_{n+1} - 8u_n \ , \ n \in IN \end{cases}$

ក.គេតាង $x_n = u_{n+1} - 2u_n$ និង $y_n = u_{n+1} - 4u_n$ ។

បង្ហាញថា (x_n) និង (y_n) ជាស៊ីតធរណីមាត្រ ។

ខ.គណនា x_n និង y_n ជាអនុគមន៍នៃ n ។

គ.ទាញរក u_n ជាអនុគមន៍នៃ n ។

ឃ.កំនត់ n ដើម្បីឲ្យ $u_n = 1049600$ ។

២៥_គេឲ្យស៊ីត $\begin{cases} u_0 = 2 \ , \ u_1 = 4 \\ 3u_{n+2} - 4u_{n+1} + u_n = 0 \ , n \in N \end{cases}$

គណនា u_n ជាអនុគមន៍នៃ n និងរក $\lim\limits_{n\to+\infty} u_n$ ។

២៦_គេឲ្យស៊ីត $\begin{cases} u_0 = \dfrac{1}{3} \\ u_{n+1} = \dfrac{2u_n}{1 + u_n^{\ 2}} \ , \ n \in IN \end{cases}$

ក.បង្ហាញថា $v_n = \ln\left(\dfrac{1-u_n}{1+u_n}\right)$ ជាស៊ីតធរណីមាត្រ ។

ខ.គណនា v_n និង u_n ជាអនុគមន៍នៃ n ។

២៧_គេឲ្យស៊ីត $\begin{cases} u_0 = \dfrac{1}{3} \\ u_{n+1} = \dfrac{u_n^{\ 2}}{2(1+u_n)} \ , \ n \in IN \end{cases}$

ក.បង្ហាញថា $v_n = \ln\left(\dfrac{2+u_n}{u_n}\right)$ ជាស៊ីតធរណីមាត្រ ។

ខ.គណនា v_n និង u_n ជាអនុគមន៍នៃ n ។

២៨_គេឲ្យស៊្វីតនៃចំនួនពិត $u_0=3$ និង $\forall n\in IN: u_{n+1}=\dfrac{u_n^2-2}{2u_n-3}$

ក. គេតាង $v_n=\dfrac{u_n-1}{u_n-2}$ ។ បង្ហាញថា $v_{n+1}=v_n^2$ រួចទាញថា $v_n=v_0^{2^n}$

ខ. គណនា u_n ជាអនុគមន៍នៃ n រួចទាញរក $\lim\limits_{n\to+\infty}u_n$ ។

២៩_គេមានអនុគមន៍ $f(x)=\dfrac{x^3-6x+6}{3x^2-9x+7}$

គេពិនិត្យស៊្វីត $u_0=3$, $u_{n+1}=f(u_n)$, $v_n=\dfrac{u_n-1}{u_n-2}$ និង $w_n=\ln v_n$

ក.ចូរស្រាយថា (w_n) ជាស៊្វីតធរណីមាត្រ រួចគណនា w_n ជាអនុគមន៍នៃ n ។

ខ.គណនា v_n រួចទាញរក u_n ជាអនុគមន៍នៃ n ។

គ.គណនា $\lim\limits_{n\to+\infty}u_n$ ។

៣០_គេមានស៊្វីត $\begin{cases} a_0=2 \\ a_{n+1}=-\dfrac{1}{8}+\dfrac{a_n-\sqrt{1+4a_n}}{4} \end{cases}$, $n\in IN$

ក.តាង $b_n=1+\sqrt{1+4a_n}$ ។ បង្ហាញថា (b_n) ជាស៊្វីតធរណីមាត្រ ។

គណនា b_n ជាអនុគមន៍នៃ n ។

ខ.គណនា a_n ជាអនុគមន៍នៃ n រួចទាញរក $\lim\limits_{n\to+\infty}a_n$ ។

៣១_គេឲ្យស៊្វីត (u_n) កំនត់លើ IN^* ដោយ ៖

$u_1=0$, $|u_2|=|1+u_1|$, ..., $\forall n\in IN^*: |u_{n+1}|=|1+u_n|$

ចូរស្រាយថា $\dfrac{u_1+u_2+u_3+.....+u_n}{n}\ge-\dfrac{1}{2}$ ។

៣២_គេឲ្យស៊្វីត (u_n) កំនត់ដោយ $\begin{cases} u_1=1 \\ u_{n+1}-u_n=\dfrac{1}{(n+1)^2} \end{cases}$, $\forall n\in IN^*$

ក.បង្ហាញថា $u_n=1+\dfrac{1}{2^2}+\dfrac{1}{3^2}+...+\dfrac{1}{n^2}$ ។

ខ. បង្ហាញថា $u_n<2$ ។

៣៣_ចូរស្រាយថា $\frac{1}{1.3}+\frac{1}{3.5}+\frac{1}{5.7}+.........+\frac{1}{(2n-1)(2n+1)}<\frac{1}{2}$ ។

៣៤_ចូរស្រាយថា $(1+\frac{1}{2})(1+\frac{1}{5}).......(1+\frac{2}{n^2+3n})<3$ ។

៣៥_គេឲ្យស្វ៊ីត $\begin{cases} u_1=1 \\ u_{n+1}=\frac{n+1}{5n}u_n \ , \ n\in IN^* \end{cases}$

ក.គណនា u_n ជាអនុគមន៍នៃ n ។

ខ.គណនាផលបូក $S_n=u_1+u_2+....+u_n$ រួចទាញរក $\lim_{n\to+\infty}S_n$ ។

៣៦_គេឲ្យអនុគមន៍ $f(x)=\frac{x}{\sqrt{1+9x^2}}$

ដោយធ្វើវិចារតាមកំនើនថា $f_n[f[\ \ f(f(x))\ \ ]\ ]=\frac{x}{\sqrt{1+9nx^2}}$

៣៧_គេឲ្យអនុគមន៍ $f(x)=\frac{x^2-2}{2x-3}\ ,\ x\neq\frac{3}{2}$ ។

គណនា $f_n[f[......f[f(x)]......]\ ]$

៣៨_គេឲ្យស្វ៊ីត $\begin{cases} a_0=4 \\ a_{n+1}=(a_n+1)(a_n+4)\ ,\ n\in IN \end{cases}$

ក.គ្រប់ $n\in IN$ ស្រាយថា a_n ចែកដាច់នឹង 4 ។

ខ.ស្រាយថា (a_n) ជាស្វ៊ីតកើនជានិច្ច ។

គ.ស្រាយថា $\left(a_{n+1}+\frac{5}{2}\right)^2>\left(a_n+\frac{5}{2}\right)$ រួចបង្ហាញថា $\lim_{n\to+\infty}a_n=+\infty$ ។

ឃ.តាង $S_n=\frac{1}{a_0+3}+\frac{1}{a_1+3}+\frac{1}{a_2+3}+.........+\frac{1}{a_n+3}$ ។ គណនា $\lim_{n\to+\infty}S_n$

៣៩_គេឲ្យ $p\in IN^*$ និង គ្រប់ $n\in IN^*$ គេមាន $u_n=\frac{(n+1)^p-n^p}{(n^2+n)^p}$ ។

តាង $S_n=u_1+u_2+u_3+........+u_n$ ។

ក. គណនា S_n ជាអនុគមន៍នៃ n និង p ។

ខ. គណនា $\lim_{n\to+\infty}S_n$ ។

៩០_គេឲ្យស្វ៊ីតនៃចំនួនគត់វិជ្ជមាន (u_n) កំនត់ដោយ ៖

$$\begin{cases} u_0 = 7 \ , \ u_1 = 35 \\ u_{n+2} = 11u_{n+1} - 18u_n \ , \ n \in IN \end{cases}$$

ចូរស្រាយថា u_n ចែកដាច់នឹង 7 ជានិច្ចគ្រប់ $n \in IN$ ។

៩១_គេឲ្យ $u_n = 1^p + 2^p + 3^p + ... + n^p$ ដែល p ជាចំនួនគត់វិជ្ជមានសេស ។

ចូរស្រាយថា u_n ចែកដាច់នឹង $\frac{n(n+1)}{2}$ ។

៩២_គេឲ្យសំណុំនៃចំនួនគត់ពីរ ៖

$E_p = \{ u_1 , u_2 , u_3 , ... , u_p \}$ និង $F_q = \{ v_1 , v_2 , v_3 , ... , v_q \}$

ដែល (u_p) ជាស្វ៊ីតនព្វន្តមានតួ 2 , 9 , 11 , 18 , 25 , ...

និង (v_q) ជាស្វ៊ីតនព្វន្តមានតួ 4 , 9 , 14 , 19 , 24 , ... ។

ក.តើសំណុំ E_{2007} មានធាតុដែលជាការេប្រាកដប៉ុន្មាន និង សំណុំ F_{2007} មានធាតុដែលជាការេប្រាកដប៉ុន្មាន ។

ខ. តើសំណុំ E_{2007} និង F_{2007} មានធាតុស្មើគ្នាប៉ុន្មាន ?

គ. តើសំណុំ E_{2007} មានធាតុចែកដាច់នឹង 3 ប៉ុន្មានធាតុ ?

ឃ. តើសំណុំ F_{2007} មានធាតុចែកដាច់នឹង 3 ប៉ុន្មានធាតុ ?

៩៣_គេឲ្យ (a_n) ជាស្វ៊ីតនៃចំនួនគត់គ្រប់ $n \in IN^*$ ។

គេមានម៉ាទ្រីសការេ $M = \begin{pmatrix} a_1 & a_2 & a_3 \\ a_4 & a_5 & a_6 \\ a_7 & a_8 & a_9 \end{pmatrix}$ ។

គេដឹងថាផលគុណនៃធាតុទាំងបីតាមជួរដេកនីមួយៗ ផលគុណនៃធាតុទាំងបីតាមជួរឈរនីមួយៗ និង ផលគុណនៃធាតុទាំងបីតាមអង្កត់ទ្រូងស្មើនឹង m ដូចគ្នា ។

បង្ហាញថា m ជាគូបនៃចំនួនគត់ ។

៩៤_គេឲ្យ $b_n = 1 + a^{2^n}$, $a > 0$, $a \neq 1$ ។ ចូរស្រាយថា $\lim\limits_{x \to 0} \left(\frac{1}{n} \sum\limits_{k=1}^{n} a_k^{\ x} \right)^{\frac{n}{x}} < \frac{1}{1-a}$ ។

៩៥_គេឲ្យស្វ៊ីត $u_n=\dfrac{1}{(3n-2)(3n+1)(3n+4)}$ ចំពោះគ្រប់ $n\in IN^*$

ក.កំនត់ពីរចំនួនពិត A និង B ដើម្បីឲ្យ ៖

$$u_n=\frac{A}{(3n-2)(3n+1)}-\frac{B}{(3n+1)(3n+4)}$$

ខ.គណនាផលបូក $S_n=u_1+u_2+u_3+...+u_n$ និង $\lim\limits_{n\to+\infty}S_n$ ។

៩៦_គេឲ្យស្វ៊ីត $u_n=\dfrac{1}{(4n-3)\sqrt{4n+1}+(4n+1)\sqrt{4n-3}}$, $n\in IN$

ក.កំនត់ពីរចំនួនពិត A និង B ដើម្បីឲ្យ ៖

$$u_n=\frac{A}{\sqrt{4n-3}}-\frac{B}{\sqrt{4n+1}}$$

ខ.គណនាផលបូក $S_n=u_1+u_2+u_3+...+u_n$ និង $\lim\limits_{n\to+\infty}S_n$ ។

៩៧_គេឲ្យស្វ៊ីត $a_n=\dfrac{6n-7}{(3n-2)(3n+1)}$, $\forall n\in IN^*$

ក.កំនត់ពីរចំនួនពិត A និង B ដើម្បីឲ្យ $a_n=\dfrac{A}{3n+1}+\dfrac{B}{3n-2}$ ។

ខ.គណនា $S_n=a_1+3a_2+3^2a_3+.....+3^{n-1}a_n$ ។

៩៨_គេឲ្យស្វ៊ីត $b_n=\dfrac{4n+9}{2^n(4n+1)(4n+5)}$ ចំពោះគ្រប់ $n\in IN$ ។

តាង $S_n=b_0+b_1+b_2+....+b_n$ ។ ចូរគណនា $\lim\limits_{n\to+\infty}S_n$ ។

៩៩_គេឲ្យស្វ៊ីត $t_n=\dfrac{9n^2-3n+2}{9n^2-3n-2}$, $\forall n\in IN^*$

ក.ចូរកំនត់បីចំនួន a , b , c ដើម្បីឲ្យ $t_n=a+\dfrac{b}{3n-2}+\dfrac{c}{3n+1}$

ខ.គណនា $S_n=t_1+t_2+t_3+.....+t_n$ រួចទាញរក $\lim\limits_{n\to+\infty}(S_n-n)$ ។

៥០_គេឲ្យស្វ៊ីត $\begin{cases}a_0=2\\ a_{n+1}=\dfrac{a_n{}^2+5a_n+1}{3}\end{cases}$, $\forall n\in IN$

គេតាង $S_n=\sum\limits_{k=0}^{n}\left(\dfrac{1}{a_k+4}\right)$ ។ ចូរគណនា $\lim\limits_{n\to+\infty}S_n$ ។

៥១-គេឱ្យអនុគមន៍ $f(x)$ កំនត់លើចន្លោះ $]0\,,\frac{\pi}{2}[$ ដោយ $f(x)=\tan x$ ។

ក. ដោយប្រើនិយមន័យចូរគណនា $f'(x)$ ចំពោះគ្រប់ $x\in]0\,,\frac{\pi}{2}[$ ។

ខ. ឧបមាថា a និង b ជាពីរចំនួនពិតនៃចន្លោះ $]0\,,\frac{\pi}{2}[$ ដែល $a<b$ ។

ចូរស្រាយថា $\forall x\in[a,b]$ គេបាន $\frac{1}{\cos^2 a}\le f'(x)\le\frac{1}{\cos^2 b}$ រួចដោយប្រើវិសមភាព

កំណើនមានកំត់ចូរទាញថា $\frac{b-a}{\cos^2 a}\le \tan b-\tan a\le\frac{b-a}{\cos^2 b}$ ។

គ. ចូររកកន្សោមអមនៃ $S_n=\frac{1}{\cos^2\frac{\theta}{n}}+\frac{1}{\cos^2\frac{2\theta}{n}}+\frac{1}{\cos^2\frac{3\theta}{n}}+\dots+\frac{1}{\cos^2\frac{n\theta}{n}}$

រួចទាញរកលីមីត $\lim\limits_{n\to+\infty}S_n$ ($\theta\in\,]0\,,\frac{\pi}{2}[$) ។

52-គេឱ្យអនុគមន៍ $f_n(x)=(1+x)(1+x^2)(1+x^4).....(1+x^{2^n})$

$$g(x)=\frac{1}{1+x}+\frac{2x}{1+x^2}+\frac{4x^3}{1+x^4}+......+\frac{2^n x^{2^n-1}}{1+x^{2^n}}$$

ក. ចូរផ្ទៀងផ្ទាត់ថា $g(x)=\frac{f'_n(x)}{f_n(x)}$

ខ. ចូរគណនា $f_n(x)$ រួចទាញ $g_n(x)$ ជាអនុគមន៍នៃ n និង x ។

គ. ចូរគណនា $\lim\limits_{n\to+\infty}f_n(x)$ និង $\lim\limits_{n\to+\infty}g_n(x)$ បើ $|x|<1$ ។

53- ចំពោះគ្រប់ $n\in IN^*$ គេមានស៊ីត $x_1=1$ និង $x_{n+1}=x_n+\frac{1}{x_n+\sqrt{n+1}}$

ចូរបង្ហាញថា $\frac{1}{x_1}+\frac{1}{x_2}+\frac{1}{x_3}+....+\frac{1}{x_n}>\frac{n}{1+\sqrt{n+1}}$ ។

54-គេឱ្យ $f(n)=4^n+5^n+6^n+7^n+9^n+11^n$ ចំពោះគ្រប់ $n\in IN^*$ ។

ក. ចូរបង្ហាញថា $f(5)=12^5$

ខ. ចំពោះគ្រប់ $n>5$ ចូរបង្ហាញថា $f(n)<12^n$ ។

55-ចូរបង្ហាញថា $\sqrt[2007]{4}+\sqrt[2007]{6}+\sqrt[2007]{8}+\sqrt[2007]{9}+\sqrt[2007]{14}>\sqrt[2007]{15}$ ។

56-គេឱ្យអនុគមន៍ $f(x)=\dfrac{2x}{x^2+1}$ ។

ចូរបង្ហាញថា $F_n(x)=f_n\left[\, f\left[\, ...f\left[\, f(x)\,\right]....\,\right]\right]=\dfrac{(1+x)^{2^n}-(1-x)^{2^n}}{(1+x)^{2^n}+(1-x)^{2^n}}$

57-ចូរប្រៀបធៀបចំនួន $A=\dfrac{2.468642}{1+(1.234321)^2}$ និង $B=\dfrac{2.468644}{1+(1.234322)^2}$

58-គេមានត្រីធា $f(x)=2007x^2+2006x+1$ ។

ចូរប្រៀបធៀបតម្លៃ $f(\log_{2006}2007)$ និង $f(\log_{2007}2008)$

59-ចំពោះគ្រប់ $n\in IN^*$ ចូរបង្ហាញថា $(2n)!\geq 2(n!)$ ។

60-ចូរស្រាយបញ្ជាក់ថា $123456789^{123456789}<(123456789!)^2$

61-មានស្វ៊ីតនៃចំនួនពិត $(u_n)_{n\in IN^*}$ កំនត់ដោយ $\begin{cases} u_1=-1 \\ u_{n+1}=\dfrac{2}{3}u_n-\dfrac{1}{2} \end{cases}$ $,\forall n\in IN^*$

ក. គេតាង $\forall n\in IN^*: v_n=2u_n+3$ ។

ចូរបង្ហាញថា (v_n) ជាស្វ៊ីតធរណីមាត្រមួយដែលគេនឹងបញ្ជាក់រេសុង ។

ខ. គណនាផលបូក $S_n=v_1+v_2+v_3+....+v_n$ ជាអនុគមន៍នៃ n ។

គ. ចូរគណនាតួ v_n រួចទាញរក u_n ជាអនុគមន៍នៃ n ។

62-គេឱ្យស្វ៊ីតនៃចំនួនពិត $(u_n)_{n\in IN^*}$ កំនត់ដោយ $\begin{cases} u_1=4 \\ u_{n+1}=\dfrac{2}{3}u_n-2(2n+\dfrac{5}{3}) \end{cases}$ $,\forall n\in IN^*$

ក. គេតាង $v_n=\dfrac{1}{2}u_n+3n-2$ ។ ចូរបង្ហាញថាស្វ៊ីត $(v_n)_{n\in IN^*}$ ជាស្វ៊ីតធរណីមាត្រ ។

ខ. គណនាផលបូក $S_n=v_1+v_2+v_3+....+v_n$ ជាអនុគមន៍នៃ n ។

គ. ចូរគណនាតួ v_n រួចទាញរក u_n ជាអនុគមន៍នៃ n ។

63-គេឱ្យស្វ៊ីត (u_n) កំនត់ដោយ $u_1=-1$ $,u_2=1$ និង $\forall n\in IN^*: u_{n+2}=5u_{n+1}-6u_n$ ។

គេតាង $v_n=u_{n+1}-2u_n$ និង $w_n=u_{n+1}-3u_n$ គ្រប់ $n\in IN^*$ ។

ក. ចូរបង្ហាញថា (v_n) និង (w_n) ជាស្វ៊ីតធរណីមាត្រ រួចគណនា v_n និង w_n ជាអនុគមន៍នៃ n ។

ខ. ទាញរកតួ u_n ជាអនុគមន៍នៃ n ។

64-គេឱ្យស្វ៊ីត (u_n) កំនត់ដោយ $\begin{cases} u_1 = 1 \\ u_{n+1} = \dfrac{3u_n + 4}{u_n + 3} \end{cases}, n \in IN^*$

បង្ហាថាស្វ៊ីត $v_n = \dfrac{u_n - 2}{u_n + 2}$,$\forall n \in IN^*$ ជាស្វ៊ីតធរណីមាត្រ រួចគណនាតួ v_n

និង u_n ជាអនុគមន៍នៃ n ។

65-គេឱ្យ f ជាអនុគមន៍ កំនត់ពីសំណុំ IN^* ទៅ IR ដោយ :

$$\begin{cases} f(1) = 2 \\ f(1) + f(2) + f(3) + ... + f(n) = n^2.f(n) \end{cases}$$

ក. គណនាតម្លៃនៃ $f(2)$ និង $f(3)$ ។

ខ. ចូរគណនា $f(n)$ ជាអនុគមន៍នៃ n ។

66-គេឱ្យស្វ៊ីតនៃចំនួនពិត (u_n) កំនត់គ្រប់ $n \in IN^*$ ដោយ $\begin{cases} u_1 = \sqrt{5} \\ u_{n+1} = u_n^{\ 2} - 2 \end{cases}$

ក. ចូរបង្ហាញថា $\forall n \in IN : u_n > 2$ ។

ខ. គេតាង $v_n = u_n + \sqrt{u_n^{\ 2} - 4}$ គ្រប់ $n \in IN^*$ ។ ចូររកទំនាក់ទំនងរវាង v_{n+1} និង v_n ។

គ. គណនា v_n ជាអនុគមន៍នៃ n រួចទាញរក u_n ជាអនុគមន៍នៃ n ។

67-គេឱ្យស្វ៊ីតនៃចំនួនពិត (u_n) កំនត់លើ IN^* ដោយ $\begin{cases} u_1 = 5 + 3\sqrt{5} \\ u_{n+1} = \dfrac{1}{2}\left(u_n + \dfrac{5}{u_n}\right) \end{cases}$

ក. គេតាង $\forall n \in IN^* : v_n = \dfrac{u_n - \sqrt{5}}{u_n + \sqrt{5}}$ ។ ចូររកទំនាក់ទំនងរវាង v_{n+1} និង v_n ។

ខ. គណនា v_n ជាអនុគមន៍នៃ n រួចទាញរក u_n ជាអនុគមន៍នៃ n ។

គ. គេតាង $w_n = 1 + v_n$ ចំពោះ $\forall n \in IN^*$ ។ គណនាផលគុណ $P_n = w_1.w_2.w_3.....w_n$

68- គេឱ្យ (U_n) ជាស្វ៊ីតនៃចំនួនពិតកំនត់ចំពោះគ្រប់ $n > 0$ ដោយ :

$$U_n = \frac{1}{\sqrt{n^2+1}} + \frac{1}{\sqrt{n^2+2}} + ... + \frac{1}{\sqrt{n^2+2n}}$$ ។

ក. ចំពោះគ្រប់ $n, p \in IN^*$ ដែល $1 \le p \le n$ ចូរបង្ហាញថា $n \le \sqrt{n^2 + p} \le n + 1$ ។

ខ. ទាញបង្ហាញថា $\frac{2n}{2n+1} \le U_n \le 2$ រួចទាញរក $\lim\limits_{n\to+\infty} U_n$ ។

69- គេមានស្វ៊ីតចំនួនពិតកំនត់ដោយ ៖

$$U_n = \frac{n}{n^2+1} + \frac{n}{n^2+2} + ... + \frac{n}{n^2+n} \ , \ n \ge 1 \quad ។$$

ក. បង្ហាញថា $\forall n \ge 1 \ ; \ \frac{n}{n^2+n} \le U_n \le \frac{n^2}{n^2+1}$ ។

ខ.ទាញរក $\lim\limits_{n\to+\infty} U_n$ ។

70- គេឱ្យស៊្វីតចំនួនពិត ៖ $\begin{cases} U_0 = \frac{\sqrt{2}}{2} \\ U_{n+1} = \frac{\sqrt{2}}{2}\sqrt{1+U_n} \ , \forall n \in IN \end{cases}$

ក. ដោយធ្វើវិចារតាមកំនើនចូរបង្ហាញថា $\frac{\sqrt{2}}{2} \le U_n \le 1$ ។

ខ. បង្ហាញថាស្វ៊ីត (U_n) មានលីមីតស្មើ L_0 មួយដែលគេនឹង កំនត់រក ។

គ. ចូរបង្ហាញតាមកំនើនថា $\forall n \in IN^* : U_n = \cos(\frac{\pi}{2^{n+2}})$ រួចទាញរកឡើងវិញនៃ $\lim\limits_{n\to+\infty} U_n$

71-គេឱ្យ $U_n = \sqrt{a+\sqrt{a+\sqrt{a+.....+\sqrt{a}}}}$ ។ ចូរបង្ហាញថា $U_n \le \frac{1+\sqrt{4a+1}}{2}$ ។

72-គេពិនិត្យស្វ៊ីត (U_n) កំនត់ដោយ ៖

$$U_n = \underbrace{\sqrt{2+\sqrt{2+\sqrt{2+.......+\sqrt{2+\sqrt{2}}}}}}_{(n)} \quad ។$$

ក. ដោយធ្វើវិចារ្យតាមកំនើនចូរបង្ហាញថា $U_n = 2\cos\frac{\pi}{2^{n+1}}$

ខ. គេមាន $V_n = \underbrace{\sqrt{2-\sqrt{2+\sqrt{2+........+\sqrt{2+\sqrt{2}}}}}}_{(n)}$ ។ ចូរស្រាយថា $V_n = 2\sin\frac{\pi}{2^{n+1}}$ ។

គ. គណនាលីមីត $\lim\limits_{n\to+\infty} U_n$ and $\lim\limits_{n\to+\infty}\left(2^n.V_n\right)$ ។

73- គេឱ្យស្វ៊ីតចំនួនពិត ៖ $\begin{cases} a_0 = 2 \ , \ b_0 = 4 \\ a_{n+1} = \frac{1}{4}(a_n + 3b_n) \\ b_{n+1} = \frac{1}{4}(3a_n + b_n) \quad , n \in IN \end{cases}$

ក. កំនត់ចំនួនពិត λ ដើម្បីឱ្យ $C_n = a_n + \lambda.b_n$ ជាស៊ីតថេរ ។

ខ. បង្ហាញថា $U_n = a_n - b_n$ ជាស៊ីតធរណីមាត្រ ។

គ. ទាញរក a_n និង b_n ជាអនុគមន៍នៃ n រួចបញ្ជាក់លីមីតវា ។

74-គេឱ្យកន្សោម $S_n = \frac{1}{\sqrt[3]{n}}\left(1 + \frac{1}{\sqrt[3]{4}} + \frac{1}{\sqrt[3]{9}} + ... + \frac{1}{\sqrt[3]{n^2}}\right)$

ក. ចំពោះគ្រប់ $x \in [n , n+1]$ និង $n \in IN^*$ ចូរស្រាយបញ្ជាក់វិសមភាព :

$$\frac{1}{\sqrt[3]{(n+1)^2}} \le \int_n^{n+1} \frac{dx}{\sqrt[3]{x^2}} \le \frac{1}{\sqrt[3]{n^2}} \quad ។$$

ខ. ទាញឱ្យបានថា $\int_1^{n+1} \frac{dx}{\sqrt[3]{n^2}} \le 1 + \frac{1}{\sqrt[3]{4}} + \frac{1}{\sqrt[3]{9}} + ... + \frac{1}{\sqrt[3]{n^2}} \le 1 + \int_1^n \frac{dx}{\sqrt[3]{x^2}}$ ។

គ. ទាញរកលីមីត $\lim\limits_{n \to +\infty} S_n$ ។

75-គេមានសមីការ $(E) : x^3 - (2m+3)x + 28x - 24 = 0$ ដែល m ជាប៉ារ៉ាម៉ែត្រ ។

ចូរកំនត់តម្លៃ m ដើម្បីឱ្យសមីការមានឫសបី x_1, x_2, x_3 បង្កើតបានជាស៊ីតនព្វន្តមួយ រួចដោះស្រាយសមីការ ។

76-គេឱ្យស៊ីតនៃចំនួនពិត (u_n) កំនត់លើសំណុំ IN^* ដោយ :

$$\begin{cases} u_1 = 1 \\ (n - \frac{1}{2})u_{n+1} - (n + \frac{1}{2}).u_n = 4n^2 - 1 \ , \forall n \in IN^* \end{cases}$$

ក. ចូរគណនាតម្លៃនៃតួ u_2, u_3 និង u_4 ។

ខ. គេតាង $v_n = \frac{1}{2n-1}.u_n$ ចំពោះគ្រប់ $n \in IN^*$ ។ បង្ហាញថា (v_n) ជាស៊ីតនព្វន្តមួយ ។

គ. ចូរគណនា v_n និង u_n ជាអនុគមន៍នៃ n ។

77-គេឱ្យស៊ីតនៃចំនួនពិត (U_n) កំនត់លើ IN ដោយ :

$$U_0 = 2006 \text{ និង } U_{n+1} = \frac{2006}{2007}U_n + 2008 , \forall n \in IN \quad ។$$

ចូរកំនត់រកតួ U_n ជាអនុគមន៍នៃ n និង $\lim\limits_{n \to +\infty} U_n$ ។

78- គេឱ្យស៊ីតនៃចំនួនពិត (U_n) កំនត់លើ IN ដោយ ៖

$U_0 = 4$ និង $U_{n+1} = 2U_n^{\frac{3}{4}}, \forall n \in IN$ ។

ចូរកំនត់រកតួ U_n ជាអនុគមន៍នៃ n និង $\lim\limits_{n\to+\infty} U_n$ ។

79-គេមានស៊ីតចំនួនពិត $\begin{cases} U_0 = -1, U_1 = 1 \\ U_{n+2} = U_{n+1} + U_n, \forall n \in IN \end{cases}$

ក-កំនត់ចំនួនពិត d ដើម្បីឱ្យស៊ីត $V_n = U_{n+1} - d.U_n, \forall n \in IN$ ជាស៊ីតធរណីមាត្រ ។

ខ-កំនត់ U_n ជាអនុគមន៍នៃ n រួចទាញរក $\lim\limits_{n\to+\infty} U_n$ ។

80-គេមានស៊ីតចំនួនពិត $\begin{cases} U_0 = 1, U_1 = 3 \\ U_{n+2} = 4U_{n+1} - 4U_n, \forall n \in IN \end{cases}$

ក-កំនត់ចំនួនពិត d ដើម្បីឱ្យស៊ីត $V_n = U_{n+1} - d.U_n, \forall n \in IN$ ជាស៊ីតធរណីមាត្រ ។

ខ-កំនត់ U_n ជាអនុគមន៍នៃ n រួចទាញរក $\lim\limits_{n\to+\infty} U_n$ ។

81-គេមានស៊ីតចំនួនពិត $\begin{cases} U_0 = -1, U_1 = 1 \\ U_{n+2} = 2U_{n+1} - 2U_n, \forall n \in IN \end{cases}$

ក-កំនត់ចំនួនកុំផ្លិច d ដើម្បីឱ្យស៊ីត $V_n = U_{n+1} - d.U_n, \forall n \in IN$ ជាស៊ីតធរណីមាត្រ ។

ខ-កំនត់ U_n ជាអនុគមន៍នៃ n រួចទាញរក $\lim\limits_{n\to+\infty} U_n$ ។

82-គេមានស៊ីតចំនួនពិត $\begin{cases} U_0 = 0, U_1 = 1 \\ U_{n+2} = 2U_{n+1} + 3U_n - 4, \forall n \in IN \end{cases}$

ក-កំនត់ចំនួនពិត d និង k ដើម្បីឱ្យស៊ីត $V_n = U_{n+1} - d.U_n + k, \forall n \in IN$

ជាស៊ីតធរណីមាត្រ ។

ខ-កំនត់ U_n ជាអនុគមន៍នៃ n រួចទាញរក $\lim\limits_{n\to+\infty} U_n$ ។

83-គេឱ្យស៊ីត $\begin{cases} U_0 = 2 \\ U_{n+1} = \dfrac{U_n^2}{2U_n - 1}, \forall n \in IN \end{cases}$

ក. ស្រាយថា $U_n > 1$ គ្រប់ $n \in IN$ ។

ខ. តាង $V_n = \ln(U_n - 1) - \ln U_n$ ។

បង្ហាញថា (V_n) ជាស៊ីតធរណីមាត្រ ។

គ. គណនា U_n ជាអនុគមន៍នៃ n រួចរក $\lim\limits_{n\to+\infty} U_n$ ។

84-គេមានស៊ីតចំនួនពិត (U_n) កំនត់លើ IN ដោយ :

$U_0 = 4$ និង $U_{n+1} = 2U_n + 3$ គ្រប់ចំនួន $n \in IN$ ។

ចូរកំនត់រកតួ U_n ជាអនុគមន៍នៃ n ។

85- គេឱ្យស៊ីតចំនួនពិត (U_n) កំនត់លើ IN ដោយ :

$U_0 = 3$ $U_1 = 4$ និង $U_{n+2} = \frac{5}{3}U_{n+1} - \frac{2}{3}U_n$ (ចំពោះគ្រប់ $n \in IN$) ។

ក. ចូរបង្ហាញថាគ្រប់ $n \in IN : U_{n+1} = \frac{2}{3}U_n + 2$ ។

ខ. កំនត់តម្លៃ k ដែល $U_{n+1} - k = \frac{2}{3}(U_n - k)$ ។

គ. គណនា U_n ជាអនុគមន៍នៃ n រួចរក $\lim\limits_{n\to+\infty} U_n$ ។

86-គេឱ្យស៊ីតចំនួនពិត (U_n) កំនត់ដោយទំនាក់ទំនង :

$U_0 = 2$ និងគ្រប់ $n \in IN$ មាន $U_{n+1} = \frac{2}{3}U_n + 4$

ក.កំនត់ចំនួនពិត λ ដើម្បីឱ្យ $V_n = U_n + \lambda$ ជាស៊ីតធរណីមាត្រ ។

ខ. គណនា U_n ជាអនុគមន៍នៃ n រួចរក $\lim\limits_{n\to+\infty} U_n$ ។

87-គេឱ្យស៊ីត $\begin{cases} U_0 = \frac{\sqrt{2}}{2} \\ U_{n+1} = 4U_n^3 - 3U_n , n \in IN \end{cases}$

ចូរស្រាយតាមកំនើនថា $U_n = \cos(\frac{3^n \pi}{4})$ ។

88-គេមានស៊ីតចំនួនពិត $(U_n), n \in IN$ កំនត់ដោយ :

$$\begin{cases} U_0 = 4 \\ U_{n+1} = 2\sqrt[3]{U_n^2} , \forall n \in IN \end{cases}$$

ក. គេតាង $\forall n \in IN : V_n = -3 + \log_2 U_n$ ។ បង្ហាញថា (V_n) ជាស៊ីតធរណីមាត្រ ។

ខ. គណនា U_n ជាអនុគមន៍នៃ n រួចរក $\lim\limits_{n\to+\infty} U_n$ ។

89-គេឱ្យស្វ៊ីតនៃចំនួនពិតមួយ (U_n) កំនត់ដោយ :

$U_0=1$ និង $U_{n+1}=-\frac{1}{U_n}+\sqrt{1+\frac{1}{U_n^2}}$ គ្រប់ $n\in IN$

ចូរស្រាយតាមកំណើនថា $U_n=\tan\frac{\pi}{2^{n+2}}$ ។

90-គេឱ្យស្វ៊ីតចំនួនពិត (U_n) កំនត់ដោយទំនាក់ទំនង :

$U_0=2$ និង $U_{n+1}^5=32U_n^4$ គ្រប់ $n\in IN$

គណនា U_n ជាអនុគមន៏នៃ n រួចរក $\lim_{n\to+\infty}U_n$ ។

91-គេមានអនុគមន៏ $f(x)$ កំនត់លើចន្លោះ $]-1\ ,1\ [$ ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ

$f(\frac{1}{2})=-\ln 3$ និង $\forall x,y\in]-1,1[:f(x)+f(y)=f(\frac{x+y}{1+xy})$

ក. គណនាតម្លៃ $f(0)$ ។

ខ. ចូរកំនត់រកអនុគមន៏ $f(x)$ ។

92-គេឱ្យអនុគមន៏ $f_n(x)$ កំនត់ដោយ :

$f_1(x)=\sqrt{6+x}-3\ ,f_2(x)=\sqrt{6+\sqrt{6+x}}-3\ ,f_3(x)=\sqrt{6+\sqrt{6+\sqrt{6+x}}}-3,.....$

$f_n(x)=\sqrt{6+\sqrt{6+\sqrt{6+.......+\sqrt{6+\sqrt{6+x}}}}}-3$ ដែល $n\in IN^*$ ។

ចូរគណនាលីមីត $L_1=\lim_{x\to3}\frac{f_1(x)}{x-3}$ និង $L_n=\lim_{x\to3}\frac{f_n(x)}{x-3}$ ។

93-គេឱ្យអនុគមន៏ $f(x)=\frac{ax^2+bx+c}{x-1}$ ដែល a,b,c ជាបីចំនួនពិត ។

ចូរកំនត់បីចំនួនពិត a ,b និង c ដើម្បីឱ្យ $f(0)=-2$ និង $\lim_{x\to1}f(x)=-1$ ។

94.គេមានអនុគមន៏ $f(x)=ax^2+bx+c$ ដែល $a\neq0,a,b,c\in IR$ និង $a+b+c=1$ ។

គណនាលីមីត $\lim_{x\to1}\frac{f[f(x)]-x}{f(x)-x}$ ជាអនុគមន៏នៃចំនួនពិត a,b,c ។

95-គេឱ្យអនុគមន៏ $f_n(x)$ កំនត់ដោយ :

$f_1(x)=\sqrt{2x+3}-3\ ,f_2(x)=\sqrt{2x+\sqrt{2x+3}}-3\ ,f_3(x)=\sqrt{2x+\sqrt{2x+\sqrt{2x+3}}}-3,.....$

$f_n(x)=\sqrt{2x+\sqrt{2x+\sqrt{2x+.......+\sqrt{2x+\sqrt{2x+3}}}}}-3$ ដែល $n\in IN^*$ ។

ចូរគណនាលីមីត $L_1=\lim\limits_{x\to 3}\dfrac{f_1(x)}{x-3}$ និង $L_n=\lim\limits_{x\to 3}\dfrac{f_n(x)}{x-3}$ ។

96-គេឱ្យស្វ៊ីតនៃចំនួនពិត (U_n) និង (V_n) កំនត់ដោយ $\begin{cases} U_0=1\ ,\ V_0=0 \\ U_{n+1}=\dfrac{5U_n-3V_n}{12} \\ V_{n+1}=\dfrac{U_n+9V_n}{12} \quad ,\ n\in IN \end{cases}$

ចូរគណនា U_n និង V_n ជាអនុគមន៍នៃ n រួចបញ្ជាក់លីមីតវា

97-គេឱ្យស្វ៊ីតនៃចំនួនពិត (U_n) និង (V_n) កំនត់ដោយ $\begin{cases} U_0=1\ ,\ V_0=4 \\ U_{n+1}=-\dfrac{1}{2}U_n-\dfrac{3}{2}V_n \\ V_{n+1}=U_n+2V_n \quad ,\ n\in IN \end{cases}$

ក-ចូរបង្ហាញថា $W_n=U_n+V_n$ ជាស្វ៊ីតធរណីមាត្រ រួចគណនា W_n ជាអនុគមន៍នៃ n ។

ខ-ចូរបង្ហាញថា $t_n=2U_n+3V_n$ ជាស្វ៊ីតថេរត្រូវកំនត់ ។

គ-ទាញរក U_n និង V_n ជាអនុគមន៍នៃ n រួចបញ្ជាក់លីមីតវា.

98- គេឱ្យស្វ៊ីត (U_n) កំនត់លើ IN ដោយ ៖

$U_0=1\ ,\ U_1=4$ និង $\forall n\in IN:\ U_{n+2}=\sqrt{U_{n+1}.U_n}$

ក-គេតាង $\forall n\in IN: V_n=\ln(\dfrac{U_{n+1}}{U_n})$ ។

ចូរបង្ហាញថា (V_n) ជាស្វ៊ីតធរណីមាត្រ រួចគណនាតួ V_n ជាអនុគមន៍នៃ n និង $\lim\limits_{n\to+\infty}V_n$

ខ-ចូរបង្ហាញថា $\sum\limits_{k=0}^{n-1}(V_k)=\ln\left(\dfrac{U_n}{U_0}\right)$ រួចទាញរក U_n ជាអនុគមន៍នៃ n និង $\lim\limits_{n\to+\infty}U_n$ ។

99-គេឱ្យស្វ៊ីត (U_n) កំនត់លើ IN ដោយ ៖

$U_0=-1\ ,\ U_1=1$ និង $U_{n+2}=\dfrac{11}{10}U_{n+1}-\dfrac{1}{10}U_n$

គណនា U_n ជាអនុគមន៍នៃ n និង $\lim\limits_{n\to+\infty}U_n$ ។

100-គេឱ្យស៊ីត (U_n) កំនត់លើ IN ដោយ $U_0 = 1$, $U_1 = 2$ និង $U_{n+2}^3 = \frac{U_{n+1}^4}{U_n}$

ក-គេតាង $V_n = \ln(\frac{U_{n+1}}{U_n})$, $\forall n \in IN$ ។

ចូរបង្ហាញថា (V_n) ជាស៊ីតធរណីមាត្រ រួចគណនាតួ V_n ជាអនុគមន៍នៃ n និង $\lim_{n\to+\infty} V_n$

ខ-គេតាង $S_n = V_0 + V_1 + V_2 + ... + V_n$ ។

បង្ហាញថា $U_n = U_0.e^{S_{n-1}}$ ។រួចទាញរក U_n ជាអនុគមន៍នៃn និងបញ្ជាក់លីមីត $\lim_{n\to+\infty} U_n$ ។

101-គេឱ្យស៊ីត (U_n) កំនត់លើ IN ដោយ $U_0 = 1$, $U_1 = 2$

និង $\forall n \in IN: U_{n+2} = U_{n+1}.U_n$ ។

ចូរគណនា U_n ជាអនុគមន៍នៃ n ។

102-គេឱ្យស៊ីតនៃចំនួនពិត $(U_n)_{n\in IN^*}$ កំនត់ដោយ :

$U_n = \frac{2n-3}{2^{n+1}}$ ចំពោះគ្រប់ $n \in IN^*$ ។

ក. ចូរផ្ទៀងផ្ទាត់ថា $U_n = \frac{2n-1}{2^n} - \frac{2n+1}{2^n}$

ខ. គណនាជាអនុគមន៍នៃ n នូវផលបូក $S_n = U_1 + U_2 + U_3 + ... + U_n$

រួចទាញរក $\lim_{n\to+\infty} S_n$ ។

103-គេឱ្យកន្សោម $S_n = \frac{1^p + 2^p + 3^p + ... + n^p}{n^{p+1}}$, $n \in IN^*$, $p \in IR$

ក. ចំពោះគ្រប់ $x \in [n , n+1]$ និង $n \in IN^*$ ចូរស្រាយបញ្ជាក់វិសមភាព :

$$n^p \le \int_n^{n+1} x^p dx \le (n+1)^p$$ ។

ខ. ទាញឱ្យបានថា $1 + \int_1^n x^p dx \le 1^p + 2^p + 3^p + ... + n^p \le \int_1^{n+1} x^p dx$ ។

គ. ទាញរកលីមីត $\lim_{n\to+\infty} S_n$ ។

104-គេមានស្វ៊ីត$(U_n)_{n\in IN^*}$ កំនត់ដោយ :

$$U_n=\frac{n}{(n^2-n+1)\sqrt{n^2+n+1}+(n^2+n+1)\sqrt{n^2-n+1}}$$

ក.កំនត់ចំនួនពិត a និង b ដើម្បីឱ្យស្វ៊ីតអាចសរសេរ :

$$U_n=\frac{a}{\sqrt{n^2-n+1}}+\frac{b}{\sqrt{n^2+n+1}}$$

ខ.គណនា $S_n=U_1+U_2+U_3+.....+U_n$ ជាអនុគមន៍នៃn

រួចទាញរកលីមីត $\lim_{n\to+\infty}S_n$ ។

105-គេឱ្យស្វ៊ីត $U_n=\frac{n^2+n+1}{n(n+1)}$ ចំពោះគ្រប់ $n\in IN^*$ ។

គេតាង $S_n=\sum_{k=1}^{n}(U_k)=U_1+U_2+U_3+.....+U_n$ ។ចូរបង្ហាញថា $S_n=\frac{n(n+2)}{(n+1)}$ ។

106-គេឱ្យស្វ៊ីត $U_n=\frac{1}{n(n+1)(n+2).....(n+k)}$

ដែល $n\in IN^*$, $k\in IN^*$ ។

ចូរគណនា$S_n=\sum_{k=1}^{n}(U_k)=U_1+U_2+U_3+.....+U_n$ ។

107-គេឱ្យ $S_n=\frac{1}{10}+\frac{2}{100}+\frac{3}{1000}+...+\frac{n}{1000...000}$ ។

ក.ចូរគណនា $T_n=S_n-\frac{1}{10}S_n$ ជាអនុគមន៍នៃ n ។

ខ.ទាញរក S_n ជាអនុគមន៍នៃ n ។

108-គេឧបមាថា $(U_n)_{,n\in IN^*}$ ជាស្វ៊ីតនព្វន្តមួយដែលមានតួ $U_1,U_2,U_3,....,U_n$

សុទ្ធតែវិជ្ជមាន ។គេតាង d ជាផលសងរួមនៃស្វ៊ីតនេះ ។

ចូរស្រាយថា $\sum_{k=1}^{n}\left(\frac{1}{U_k\sqrt{U_{k+1}}+U_{k+1}\sqrt{U_k}}\right)=\frac{1}{d}\left(\frac{1}{\sqrt{U_1}}-\frac{1}{\sqrt{U_{n+1}}}\right)$

109-គេមានអនុគមន៍ $f(x)=\ln(1+x)$, $x>0$ ។

ក.ចូរបង្ហាញថា $x-\frac{x^2}{2}\le f(x)\le x$ ។

ខ.គេមាន $P_n=(1+\frac{1}{n^2})(1+\frac{2}{n^2})(1+\frac{3}{n^2})....(1+\frac{n}{n^2})$ ។ ចូរផ្ទៀងផ្ទាត់ថា $P_n=e^{\sum_{k=1}^{n}\left[f\left(\frac{k}{n^2}\right)\right]}$ ។

គ.រកកន្សោមអមនៃ $\sum_{k=1}^{n}\left[f\left(\frac{k}{n^2}\right)\right]$ រួចទាញរកលីមីត

$$\lim_{n\to+\infty} P_n = \lim_{n\to+\infty}\left[(1+\frac{1}{n^2})(1+\frac{2}{n^2})(1+\frac{3}{n^2})...(1+\frac{n}{n^2})\right]$$

110-គេមានអនុគមន៍ $f(x)=\sin x$, $x\in IR$

ក. ចូរស្រាយថា $x-\frac{x^3}{6} \le f(x) \le x$ គ្រប់ $x\in IR$ ។

ខ. គេពិនិត្យផលបូក $S_n=\sin\frac{1}{n^2}+\sin\frac{2}{n^2}+\sin\frac{3}{n^2}+......+\sin\frac{n}{n^2}$ ។

ចូររកកន្សោមអមនៃផលបូកនេះ ។

គ. ចូរគណនា $\lim\limits_{n\to+\infty} S_n$ ។

111-គេឱ្យអនុគមន៍ $f(x)=\frac{4x}{\sqrt{x^2+16}}$

ចូរគណនា $F_n(x)=f_n\left[f[....f[f(x)].....]\right]$ ។

112-គេឱ្យអនុគមន៍ $f(x)=\frac{x}{\sqrt{4+x^2}}$

ចូរគណនា $F_n(x)=f_n\left[f[....f[f(x)].....]\right]$ ។

113-គេឱ្យអនុគមន៍ $f(x)=\frac{2x}{\sqrt[3]{5+4x^3}}$

ចូរគណនា $F_n(x)=f_n\left[f[....f[f(x)].....]\right]$ ។

114-គេឱ្យអនុគមន៍ $f(x)=\frac{x^3+3x}{3x^2+1}$

ចូរគណនា $F_n(x)=f_n\left[f[....f[f(x)].....]\right]$ ។

115-គេឱ្យអនុគមន៍ $f(x)=\frac{2-2x+5x^2}{1+8x-2x^2}$

ចូរគណនា $F_n(x)=f_n\left[f[....f[f(x)].....]\right]$ ។

116-គេមានស្វ៊ីតនៃចំនួនពិត (U_n) កំនត់ដោយ $U_1=1$ និង $\forall n\in IN^*: U_{n+1}=\frac{2U_n}{\sqrt[3]{8+{U_n}^3}}$

ក.ចូររកប្រភេទនៃស្វ៊ីត $V_n=\frac{1}{U_n^3}$ ។

ខ. គណនា U_n ជាអនុគមន៍នៃ n ។

117- គេមានស្វ៊ីតនៃចំនួនពិត (U_n) កំនត់ដោយ $U_1 = 1$ និង $\forall n \in IN^* : U_{n+1} = \dfrac{U_n}{\sqrt[5]{4 + U_n^5}}$

ក.ចូររកប្រភេទនៃស្វ៊ីត $V_n = \dfrac{4^n}{U_n^5}$ ។

ខ. គណនា U_n ជាអនុគមន៍នៃ n ។

118-គេមានអនុគមន៍ $f(x) = x^3 + -6x^2 + 12x - 6$

ក. ចូរគណនា $F_n(x) = f_n\left[f[....f[f(x)].....]\right]$

ខ. កំនត់ x ដើម្បីឱ្យ $F_n(x) = 1$ ។

119*-គេមានអនុគមន៍ $f(x) = \dfrac{x^3}{3x^2 + 3x + 1}$

ក. ចូរបង្ហាញថា $1 + f(x) > 0$, $\forall x > -1$ ។

ខ. គេពិនិត្យស្វ៊ីតនៃចំនួនពិត (U_n) , (V_n) កំនត់ដោយ $\begin{cases} U_1 = f(x) , \forall x > -1 \\ U_{n+1} = f(U_n) \\ V_n = \dfrac{U_n}{1 + U_n} \qquad , n \in IN^* \end{cases}$

ចូរបង្ហាញថា $V_{n+1} = V_n^{\ 3}$ ចំពោះគ្រប់ $n \in IN^*$ ។

120-គេមានអនុគមន៍ $f(x) = \dfrac{2x}{x^2 + 4}$ ។

ក. ចូរបង្ហាញថា $-2 \le f(x) \le 2$, $\forall x \in IR$ ។

ខ. គេមានស្វ៊ីត $\begin{cases} U_1 = f(x) \\ U_{n+1} = f(U_n) , \forall n \in IN^* \end{cases}$

ចូរស្រាយថា $\dfrac{2 - U_{n+1}}{2 + U_{n+1}} = \left(\dfrac{2 - U_n}{2 + U_n}\right)^2$?

គ. ចូរទាញរក U_n ជាអនុគមន៍ n និង x ។

121-គេមានអនុគមន៍ $f(x) = x^2 - 2$

គេមានស្វ៊ីត $\begin{cases} U_1 = f(x) \\ U_{n+1} = f(U_n) , \forall n \in IN^* \end{cases}$

ក. ចូរស្រាយថាបើ $x>2$ នោះ គេបាន $\forall n\in IN^*: U_n>2$ ។

ខ. គេឧបមាថា $x>2$ ។ គេបង្កើតស្វ៊ីត $V_n=U_n+\sqrt{U_n^2-4}$ $,\forall n\in IN^*$

ចូររកទំនាក់ទំនងរវាង V_{n+1} និង V_n ។

គ. ចូរគណនា V_n និង U_n ជាអនុគមន៍ n និង x ។

ឃ. ប្រើលទ្ធផលខាងលើចូរគណនាអនុគមន៍ ចូរគណនា $F_n(x)=f_n\left[f[\ldots.f[f(x)].....]\right]$